ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន
លេខ: ៥៧៤៣/ប្រកាស/អនជ

ប្រកាស
ស្តីពី
ការបង្កើតតំបន់អភិរក្សជម្រក និងប្រភពដើមធនធានជីវសត្វក្រពើតុំ «បឹងទាលវែង»

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៨ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦២៣/០០៧ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើក្រមបរិស្ថាននិងធនធានធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ២៤១ អនក្រ.បក ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន

អគារមេតេកតេជោ ដីឡូតិ៍លេខ503 ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ទូរស័ព្ទ: 023 213 908 / 023 220 369

- បានឃើញអនុក្រឹត្យលេខ ១៧៣ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ ស្តីពី ការបង្កើតឧទ្យានជាតិជ្រលង្គក្រវាញ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងបរិស្ថាន

សម្រេច

ប្រការ១..

ត្រូវបានបង្កើតតំបន់អភិរក្សជម្រក និងប្រភពដើមធនធានពន្ធុសត្វក្រពើភ្នំ «បឹងវាលវែង» ស្ថិតក្នុងតំបន់ឧទ្យានជាតិជ្រលង្គក្រវាញ ក្នុងគោលបំណង៖

- ការពារនិងអភិរក្សសត្វក្រពើភ្នំ សំបុកពងកូន និងទីជម្រកក្នុងតំបន់ប្រព័ន្ធអេកូឡូស៊ីដើម
- សិក្សា ជ្រាវជ្រាវ អំពីលក្ខណៈជីវសាស្ត្រ ការបង្កកំណើតនិងលក្ខខណ្ឌអេកូឡូស៊ី
- រក្សាគុណតម្លៃផ្នែកវប្បធម៌ និងជំនឿសាសនាក្នុងតំបន់ក៏ដូចជាតម្លៃទេសភាពផងដែរ
- លើកកម្ពស់ការយល់ដឹងតាមរយៈការផ្សព្វផ្សាយអំពីសារប្រយោជន៍ ការការពារ ការអភិរក្សសត្វក្រពើភ្នំ និងការបណ្តុះបណ្តាលអំពីបច្ចេកទេស វិធីសាស្ត្រសង្គ្រោះ រក្សាតំណពូជដោយធម្មជាតិ ការបង្កាត់ពូជសម្រាប់សហគមន៍មូលដ្ឋាន សាធារណជន ដៃគូរពាក់ព័ន្ធ និងអង្គភាពពាក់ព័ន្ធ
- លើកទឹកចិត្តដល់ប្រជាសហគមន៍មូលដ្ឋាន សាធារណជន ដៃគូអភិវឌ្ឍ និងអង្គភាពពាក់ព័ន្ធឱ្យចូលរួមចលនារក្សាតំណពូជ ជម្រកពងកូន ឬការបង្កាត់ពូជ និងលើកកម្ពស់ការការពារ និងការអភិរក្សប្រភពអេកូឡូស៊ីដើម
- ផ្តល់ឱកាសសម្រាប់ សិស្ស និស្សិត មន្ត្រីរាជការ និងអ្នកពាក់ព័ន្ធផ្សេងទៀត ដើម្បីធ្វើការសិក្សាស្រាវជ្រាវអំពីសត្វក្រពើភ្នំ
- ជំរុញនិងពង្រីកចលនាតំណពូជតាមរយៈបង្កកំណើតពងកូនដោយធម្មជាតិឬការបង្កាត់ពូជ និងអភិរក្សនៅក្រៅតំបន់អេកូឡូស៊ីប្រភពដើម។

ប្រការ២..

តំបន់អភិរក្សជម្រក និងប្រភពដើមធនធានពន្ធុសត្វក្រពើភ្នំ «បឹងវាលវែង» មានផ្ទៃដីទំហំ ៣១៥,១១(បីរយដប់ប្រាំក្បៀសដប់មួយ)ហិកតា ស្ថិតក្នុងទីតាំងរដ្ឋបាលឃុំអូរសោម ស្រុកវាលវែង ខេត្តពោធិ៍សាត់ ដែលមានទីតាំងភូមិសាស្ត្រជាប្រព័ន្ធខ្សែព្រំបិទជិត ដែលជាឧបសម្ព័ន្ធនៃប្រកាសនេះ និងចំណុចនិយាមកាដូចខាងក្រោម៖

NO	X	Y	NO	X	Y
1	308616	1332115	20	311550	1332469
2	308742	1332116	21	311582	1332480
3	309078	1332126	22	311589	1332403
4	309281	1332096	23	311693	1332227
5	309752	1332115	24	311724	1332067
6	309872	1332081	25	311612	1331982
7	310055	1332237	26	310935	1331906
8	310072	1332283	27	310776	1331358
9	309957	1332413	28	310647	1331012
10	310207	1332462	29	310088	1330932
11	310223	1332434	30	309030	1330923

12	311061	1332483	31	308804	1331094
13	311198	1332563	32	308812	1331514
14	311213	1332553	33	308718	1331770
15	311345	1332561	34	308645	1331766
16	311409	1332531	35	308609	1331860
17	311437	1332529	36	308622	1331874
18	311435	1332504	37	308588	1331953
19	311526	1332510			

(Datum WGS 1984)។

ប្រការ៣..

តំបន់អភិរក្សជម្រក និងប្រភពដើមធនធានពន្ធុសត្វក្រពើភ្នំ «បឹងវាលវែង» ស្ថិតនៅក្រោមសមត្ថកិច្ចគ្រប់គ្រងនិងការទទួលខុសត្រូវរបស់មន្ទីរបរិស្ថានខេត្តពោធិ៍សាត់។

គោលការណ៍គ្រប់គ្រងតំបន់អភិរក្សជម្រក និងប្រភពដើមធនធានពន្ធុសត្វក្រពើភ្នំ «បឹងវាលវែង» ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន តាមសំណើរបស់អគ្គនាយកដ្ឋានតំបន់ការពារធម្មជាតិ។

ប្រការ៤..

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៥..

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន ប្រធាននាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ប្រធាននាយកដ្ឋាននីតិកម្ម ប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងបរិស្ថាន និងប្រធានមន្ទីរបរិស្ថានខេត្តពោធិ៍សាត់ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ៣ ៤ រោច ខែ ផល្គុន ឆ្នាំ មមី អដ្ឋស័ក.ព.ស.២៥៧០
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ២០២៦

រដ្ឋមន្ត្រី

អ៊ាង សុផល្លែត

កន្លែងទទួល:
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងមហាផ្ទៃ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ឧទ្ធកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ឧទ្ធកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលខេត្តពោធិ៍សាត់
- រាជកិច្ច
- ដូចប្រការ ៥
- ឯកសារ កាលប្បវត្តិ